# *សារសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូសម្រាប់រដូវអប់រំពិសេស២០២២*

*LENT 2022*

* * *

«យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់ យើងនឹងច្រូតបានផលជាមិនខាន។ ហេតុនេះ ពេលយើងមានឱកាសនៅឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់» (កាឡាទី ៦,៩-១០)។

## បងប្អូនជាទីស្រឡាញ់

រដូវ៤០ថ្ងៃ ឬរដូវអប់រំពិសេសគឺជាពេលវេលាដ៏សំខាន់ ដើម្បីចាប់ផ្តើមសារជាថ្មីសម្រាប់បុគ្គលម្នាក់ៗ និងសហគមន៍ ធ្វើដំណើរឆ្ពោះទៅរកបុណ្យចម្លងរបស់ព្រះយេស៊ូគ្រីស្ត ដែលសោយព្រះទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។ ការធ្វើដំណើរក្នុងអំឡុងពេលរដូវអប់រំពិសេសឆ្នាំ២០២២នេះ យើងគប្បីរួមគ្នារិះគិតអំពីពាក្យទូន្មានរបស់សន្តប៉ូលនៅក្នុងលិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងកាឡាទីថា៖ «យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់ យើងនឹងច្រូតបានផលជាមិនខាន។ ហេតុនេះ ពេលយើងមានឱកាសនៅឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់» (កាឡាទី ៦,៩-១០)។

## ១. ការសាបព្រោះ និងការប្រមូលផល

ឃ្លាព្រះបន្ទូលខាងលើនេះ គ្រីស្តទូតប៉ូលលើកយកនិមិត្តរូបអំពីការសាបព្រោះ និងការប្រមូលផល ដែលមានសារសំខាន់សម្រាប់ព្រះយេស៊ូ(ម៉ាថាយ ១៣)។ គ្រីស្តទូតប៉ូលថ្លែងឱ្យយើងដឹងអំពី ***ឱកាស*** គឺជាពេលវេលាដ៏សំខាន់សម្រាប់សាបព្រោះអំពើល្អដើម្បីអាចប្រមូលផលបាន។ តើឱកាសសម្រាប់យើងសាបព្រោះអំពើល្អនៅពេលណា? ពិតមែន នៅក្នុងរដូវអប់រំពិសេសគឺជាឱកាសល្អ ប៉ុន្តែ គ្រប់ពេលវេលាទាំងអស់នៃជីវិតរបស់មនុស្សនៅក្នុងលោកនេះ គឺជាឱកាសសម្រាប់ប្រព្រឹត្តអំពើល្អ។ រីឯ រដូវអប់រំពិសេសគ្រាន់តែជានិមិត្តរូបមួយ[1]។ នៅក្នុងជីវិតរបស់យើង យើងមានចិត្តអំនួត មានចិត្តលោភលន់មិនចេះស្កប់ស្កល់ យើងតែងតែមានចិត្តចង់បានហើយចង់បានទៀត ដូចមានថ្លែងជាពាក្យប្រស្នាក្នុងគម្ពីរដំណឹងល្អស្តីអំពីបុរសឆោតល្ងង់ម្នាក់ដែលអរសប្បាយ ហើយពឹងផ្អែកលើភោគផលស្តុកស្តម្ភ ដែលគាត់បានប្រមូលទុកនៅក្នុងជង្រុក(លូកា ១២,១៦-២១)។ រដូវអប់រំពិសេសអញ្ជើញយើងឱ្យកែប្រែចិត្តគំនិត ផ្លាស់ប្តូរការគិត ដើម្បីឱ្យជីវិតមានសេចក្តីពិត និងមានសោភ័ណភាព ដោយអាស្រ័យលើការធ្វើទាន ជាជាងការចង់បានធ្វើជាកម្ម

សិទ្ធិ និងដោយអាស្រ័យលើការសាបព្រោះទង្វើល្អ ព្រមទាំងចេះចែករំលែក ជាជាងការចង់បានហើយចង់បានទៀតឥតឈប់ឈរ។

កសិករទី១គឺជាព្រះជាម្ចាស់ផ្ទាល់ប្រកបដោយព្រះហឫទ័យសប្បុរស «បន្តសាបព្រោះសេចក្ដីល្អក្នុងមនុស្ស» (Enc. Fratelli tutti, លេខ ៥៤)។ នៅក្នុងអំឡុងពេលរដូវអប់រំពិសេស ព្រះជាម្ចាស់ត្រាស់ហៅយើងឱ្យឆ្លើយតបដោយស្ដាប់ព្រះបន្ទូល «ដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិ» (ហប ៤,១២)។ យើងយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ ដើម្បីញ៉ាំងឱ្យមានចិត្តស្លូតបូត(យ៉ាកុប ១,២១) នាំឱ្យជីវិតអាចបង្កើតផលផ្លែបានល្អ។ ប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅយើងឱ្យស្ដាប់ព្រះបន្ទូល នាំឱ្យយើងមានអំណរទៅហើយ ចុះទម្រាំបើព្រះអង្គត្រាស់ហៅយើងឱ្យ «ធ្វើការរួមជាមួយព្រះអង្គ»(១កូរិនថូស ៣,៩) ដើម្បីសាបព្រោះទង្វើល្អ ក្នុងពេលបច្ចុប្បន្នកាលនេះ (អេភេសូ ៥,១៦) នោះយើងនឹងរឹតតែមានអំណរថែមទៀតជាពុំខាន។ កុំគិតថា ការត្រាស់ហៅឱ្យសាបព្រោះទង្វើល្អក្លាយជាបន្ទុកឡើយ គប្បីយល់ថាជាព្រះអំណោយទានដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្រួបបង្រួមយើងឱ្យចូលរួមយ៉ាងសកម្មក្នុងគម្រោងការរបស់ព្រះអង្គ។

ចំណែកឯការប្រមូលផលវិញ? តើយើងសាបព្រោះ មិនមែនដើម្បីប្រមូលផលទេឬ? ពិតមែនការសាបព្រោះដើម្បីប្រមូលផល។ សន្តប៉ូលបានបញ្ជាក់យ៉ាងច្បាស់អំពីទំនាក់ទំនងរវាងការសាបព្រោះ និងការប្រមូលផល ដោយរម្លឹកយ៉ាងច្បាស់ថា: «អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានផលតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិបូណ៌ ក៏ច្រូតបានផលច្រើនបរិបូណ៌ដែរ»(២កូរិនថូស ៩,៦)។ តើប្រមូលផលអ្វី? ផលដំបូងដែលបានសាបព្រោះ គឺនៅក្នុងខ្លួនយើង និងនៅក្នុងទំនាក់ទំនងប្រចាំថ្ងៃរបស់យើង រហូតដល់ទង្វើតូចតាចដ៏ល្អ។ ក្នុងព្រះជាម្ចាស់ គ្រប់ទង្វើនៃសេចក្ដីស្រឡាញ់ និងចិត្តសប្បុរសទាំងអស់ ទោះបីតូចតាចក្ដី មិនចេះសាបសូន្យឡើយ (សូមមើល *អំណរហូរមកពីដំណឹងល្អ* លេខ ២៧៩)។ អំពើល្អសាយក្លិនក្រអូបរបស់ព្រះគ្រីស្តដល់ពិភពលោក (២កូរិនថូស ២,១៥) ដូចគេស្គាល់ដើមឈើតាមរយៈផ្លែរបស់វា(ម៉ាថាយ ៧,១៦-២០) ដូចជីវិតមានពន្លឺត្រចេះត្រចង់ដោយសារអំពើល្អ (ម៉ាថាយ ៥,១៤-១៦)។ ការបម្រើព្រះជាម្ចាស់ដោយមិនប្រព្រឹត្តអំពើបាប នឹងប្រមូលផលភាពដ៏វិសុទ្ធសម្រាប់ការសង្គ្រោះរបស់មនុស្សទាំងអស់(រ៉ូម ៦,២២)។

ជាការពិត យោងតាមសុភាសិតក្នុងគម្ពីរដំណឹងល្អ: «ម្នាក់ព្រោះ ម្នាក់ទៀតច្រូត» (យ៉ូហាន ៤,៣៧) នាំឱ្យយើងអាចមើលឃើញផលផ្លែមួយចំណែកតូចដែលយើងបានសាបព្រោះ។ ការសាបព្រោះទង្វើល្អចំពោះអ្នកដទៃ បានចូលរួមយ៉ាងខ្ពង់ខ្ពស់ជាមួយព្រះជាម្ចាស់: «ការដាក់សេចក្ដីសង្ឃឹមរបស់យើងក្នុងឫទ្ធានុភាពដ៏អាថ៌កំបាំងនៃគ្រាប់ពូជដែលយើងសាបព្រោះ ហើយទុកឱ្យវាបង្កើតផលដើម្បីឱ្យអ្នកដទៃប្រមូលពិតជាការប្រពៃណាស់» (Fratelli tutti, លេខ ១៩៦)។ សាបព្រោះអំពើល្អចំពោះអ្នកដទៃ ជួយយើងឱ្យរំដោះ

ខ្លួនចេញពីគំនិតនៃការចង់ចំណេញសម្រាប់តែខ្លួនឯង ហើយផ្តល់ឱ្យយើងចេះប្រព្រឹត្តទង្វើដោយមិនគិតពីរង្វាន់ ដើម្បីចូលរួមក្នុងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

ព្រះបន្ទូលព្រះជាម្ចាស់ជួយយើងឱ្យចេះមើលទូលំទូលាយ និងខ្ពង់ខ្ពស់។ ព្រះបន្ទូលប្រកាសឱ្យយើងដឹងអំពីការប្រមូលផលពិតប្រាកដនៅគ្រាអវសានកាលនៃពិភពលោក គឺនៅគ្រាចុងក្រោយបំផុត ពេលគឺពេលចុងក្រោយដែលគ្មានព្រះអាទិត្យអស្តង្គត។ ផលផ្លែ និងទង្វើនៅក្នុងជីវិតរបស់យើងគឺ «ផលផ្លែនៃជីវិតអស់កល្បជានិច្ច» (យ៉ូហាន ៤,៣៦) ដែលជា «កំណប់របស់យើងនៅស្ថានបរមសុខ» (លូកា ១២,៣៣; ១៨,២២)។ ព្រះយេស៊ូប្រើប្រាស់និមិត្តរូបអំពីគ្រាប់ពូជ ដែលងាប់នៅក្នុងដី ហើយបង្កើតផល ដើម្បីឆ្លុះបញ្ចាំងអំពីការអាថ៌កំបាំងដែលព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ(យ៉ូហាន ១២,២៤)។ សន្តប៉ូលបានលើកយកនិមិត្តរូបនេះ ដើម្បីថ្លែងអំពីរូបកាយរបស់យើងដែលរស់ឡើងវិញ «រូបកាយដែលគេកប់ក្នុងដីរមែងតែងតែរលួយ រីឯរូបកាយដែលរស់ឡើងវិញ មិនចេះរលួយទេ។ រូបកាយដែលគេកប់ក្នុងដីជារូបកាយដ៏ថោកទាប រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយសិរីរុងរឿង រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ទន់ខ្សោយ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយឫទ្ធានុភាព។ រូបកាយដែលគេកប់ក្នុងដីជារូបកាយធម្មជាតិ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយព្រះវិញ្ញាណ។» (១កូរិនថូស ១៥,៤២-៤៤)។ សេចក្តីសង្ឃឹមដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញផ្តល់ឱ្យពិភពលោកនេះមានពន្លឺត្រចេះត្រចង់ «ប្រសិនបើយើងសង្ឃឹមទៅលើព្រះគ្រីស្ត សម្រាប់តែជីវិតនេះប៉ុណ្ណោះទេ យើងជាអ្នកវេទនាជាងគេបំផុតក្នុងចំណោមមនុស្សទាំងអស់ហើយ! ប៉ុន្តែ ព្រះគ្រីស្តពិតជាមានព្រះជន្មរស់ឡើងវិញមែន។ ក្នុងចំណោមមនុស្សស្លាប់ ព្រះអង្គមានព្រះជន្មរស់ឡើងវិញមុនគេបង្អស់។» (១កូរិនថូស ១៥,១៩-២០)។ ចំពោះអស់អ្នកដែលរួមក្នុងសេចក្តីស្រឡាញ់ជាមួយព្រះគ្រីស្ត «ក៏នឹងបានរួមជាមួយព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញដែរ» (រ៉ូម ៦,៥) គឺបានរួមជាមួយព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញសម្រាប់ជីវិតអស់កល្បជានិច្ច(យ៉ូហាន ៥,២៩)។ «មនុស្សសុចរិតវិញ គេនឹងស្ថិតនៅក្នុងព្រះរាជ្យនៃព្រះបិតារបស់គេ ទាំងបញ្ចេញរស្មីភ្លឺដូចព្រះអាទិត្យ»(ម៉ាថាយ ១៣,៤៣)។

## ២. យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ

ព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញប្រទានឱ្យយើងមានសេចក្តីសង្ឃឹម គឺ«សេចក្តីសង្ឃឹមថានឹងបាន» ជីវិតអស់កល្បជានិច្ចនៅក្នុងលោកនេះ និងផ្តល់ឱ្យយើងទទួលការសង្គ្រោះនាពេលបច្ចុប្បន្ននេះផងដែរ (BENOIT XVI, Enc. Spe salvi, លេខ ៣ និង ៧)។ ការប្រឈមមុខនឹងភាពល្វីងជូចត់ចំពោះការខកចិត្តក្នុងក្តីស្រម៉ៃ ការប្រឈមមុខនឹងក្តីបារម្ភចំពោះឧបសគ្គដែលកើតមាននៅចំពោះមុខ ការប្រឈមមុខនឹងការធ្លាក់ទឹកចិត្តចំពោះភាពក្រីក្រដែលខ្វះមធ្យោបាយដោះស្រាយ នាំឱ្យមានការល្បួងបែរទៅរកការពឹងពាក់

តែលើភាពអាត្មានិយមផ្ទាល់ខ្លួន និងពឹងផ្អែកទៅលើទុក្ខលំបាករបស់អ្នកដទៃ។ ជាក់ស្តែង ទោះបីមនុស្សមានកម្លាំងដ៏អស្ចារ្យយ៉ាងណា ក៏មនុស្សនៅមានព្រំដែន «ក្មេងជំទង់ៗតែងនឿយហត់ និងអស់កម្លាំង ហើយមនុស្សពេញកម្លាំងក៏តែងភ្លាត់ដួល» (អេសាយ ៤០,៣០) តែព្រះជាម្ចាស់ «ព្រះអង្គប្រទានកម្លាំងពលំដល់អ្នកនឿយហត់ និងខ្សោះល្វើយ[...] រីឯអ្នកជឿសង្ឃឹមលើព្រះអម្ចាស់ តែងតែមានកម្លាំងថ្មីជានិច្ច ប្រៀបបាននឹងសត្វឥន្ទ្រីហោះហើរ គេស្ទុះរត់ទៅមុខ ដោយមិនចេះហត់ ហើយដើរដោយមិនចេះអស់កម្លាំង។» (អេសាយ ៤០,២៩.៣១)។ រដូវអប់រំពិសេសរម្លឹកយើងឱ្យធ្វើជំនឿ និងសេចក្តីសង្ឃឹមក្នុងព្រះអម្ចាស់ (១សិលា ១,២១) ដ្បិតមានតែការសម្លឹងមើលព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញប៉ុណ្ណោះ (ហេប្រឺ ១២,២) ទើបអាចឱ្យយើងស្តាប់ពាក្យដែលគ្រីស្តទូតបានទូន្មានៈ «យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ» (កាឡាទី ៦,៩)។

យើងមិនត្រូវនឿយណាយនឹងការអធិដ្ឋានឡើយ។ ព្រះយេស៊ូបានបង្រៀន ត្រូវតែ«អធិដ្ឋានឥតឈប់ឈរ»(លូកា ១៨,១)។ យើងត្រូវអធិដ្ឋាន ដ្បិតយើងត្រូវការព្រះជាម្ចាស់។ ការយល់ឃើញថា ការពឹងផ្អែកតែលើកម្លាំងខ្លួនឯងគឺគ្រប់គ្រាន់ហើយ ជាការយល់ច្រឡំដ៏គ្រោះថ្នាក់។ ប្រសិនបើជំងឺរាតត្បាតបង្ករផលប៉ះពាល់ឱ្យយើងទទួលស្គាល់ពីភាពទន់ខ្សោយទាំងបុគ្គល និងសង្គម សូមឱ្យរដូវអប់រំពិសេសនេះជួយយើងឱ្យមានបទពិសោធន៍ជំនឿរឹងប៉ឹងក្នុងព្រះជាម្ចាស់ ដែលជាទីពឹងរបស់យើង (អេសាយ ៧,៩)។ គ្មាននរណាម្នាក់អាចសង្គ្រោះខ្លួនឯងបានឡើយ ដ្បិតយើងទាំងអស់គ្នានៅក្នុងទូកដែលត្រូវខ្យល់ព្យុះនៃប្រវត្តិសាស្រ្តកំពុងបក់បោក[2]។ គ្មាននរណាម្នាក់អាចសង្គ្រោះខ្លួនឯងដោយគ្មានព្រះជាម្ចាស់បានឡើយ ដ្បិតមានតែការអោចកំបាំងនៃបុណ្យចម្លងរបស់ព្រះយេស៊ូគ្រីស្តប៉ុណ្ណោះ ដែលផ្តល់ជ័យជំនះនៅលើទឹកនៃសេចក្តីស្លាប់។ ជំនឿមិនបង្វែរទុក្ខលំបាកចេញពីជីវិតរបស់យើងទេ តែជំនឿផ្តល់ឱ្យយើងឆ្លងកាត់ទុក្ខលំបាកទាំងនោះដោយរួមជាមួយព្រះជាម្ចាស់ក្នុងអង្គព្រះយេស៊ូគ្រីស្ត ដែលប្រទានឱ្យយើងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំ និងមិនបណ្តោយឱ្យយើងខកចិត្តឡើយ ហើយព្រះវិញ្ញាណដ៏វិសុទ្ធក៏ចាក់បង្ហូរសេចក្តីស្រឡាញ់មកបញ្ជាំក្នុងចិត្តរបស់យើងផងដែរ(រ៉ូម ៥,១-៥)។

យើងមិនត្រូវនឿយណាយនឹងការលុបបំបាត់អំពើអាក្រក់ចេញពីក្នុងជីវិតរបស់យើងឡើយ។ សូមឱ្យការតមអាហារខាងរូបកាយក្នុងរដូវអប់រំពិសេស ពង្រឹងស្មារតីរបស់យើងប្រឆាំងនឹងអំពើបាប។ យើងមិនត្រូវនឿយណាយនឹងការស្នើសុំការលើកលែងទោសក្នុងអគ្គសញ្ញាស្រាយបាប និងសម្រុះសម្រួលឡើយ។ យើងគប្បីដឹងថា ព្រះជាម្ចាស់មិននឿយហត់នឹងលើកលែងទោសឱ្យយើងនោះទេ[3]។ យើងមិនត្រូវនឿយណាយប្រឆាំងនឹងកាមតណ្ហាឡើយ។ វាគឺជាភាពទន់ខ្សោយដែលជំរុញយើងឱ្យក្លាយទៅជាអាត្មានិយម និងប្រព្រឹត្តអំពើអាក្រក់គ្រប់យ៉ាង។ នៅគ្រប់សម័យទាំងអស់ គេសង្កេតឃើញមនុស្សមាន

មធ្យោបាយជាច្រើន ដែលបណ្ដាលឱ្យខ្លួនធ្លាក់ទៅក្នុងអំពើបាប (cf. Enc. Fratelli tutti, លេខ ១៦៦)។ មធ្យោបាយទាំងនោះរួមមាន ការញៀននឹងបណ្ដាញព័ត៌មានឌីជីថល ដែលញ៉ាំងឱ្យទំនាក់ទំនងរបស់មនុស្សកាន់តែខ្សោយទៅ។ រដូវអប់រំពិសេសគឺជាពេលវេលាដ៏សំខាន់ ដើម្បីប្រឆាំងរាល់ឧបសគ្គទាំងនេះ ហើយជួយឱ្យយកចិត្តទុកដាក់បង្កើតទំនាក់ទំនងទាំងស្រុងជាមួយគ្នាទៅវិញទៅមក (*ឯកសារដដែល* លេខ ៤៣) គឺការបង្កើតទំនាក់ទំនងជាក់ស្ដែង (*ឯកសារដដែល* លេខ ៥០) ទល់មុខគ្នា។

យើងមិននឿយណាយនឹងប្រព្រឹត្តអំពើល្អ ដោយធ្វើកិច្ចការសប្បុរសជាក់ស្ដែងចំពោះបងប្អូនឯទៀតឡើយ។ ក្នុងរដូវអប់រំពិសេស យើងធ្វើទានដោយមានចិត្តអរសប្បាយ (២កូរិនថូស ៩,៧)។ ព្រះអង្គដែល«ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងដែរ» (២កូរិនថូស ៩,១០) ដើម្បីផ្គត់ផ្គង់ឱ្យយើងម្នាក់ៗ មិនមែនគ្រាន់តែមានអាហារបរិភោគប៉ុណ្ណោះទេ គឺឱ្យយើងចេះចែករំលែកដោយចិត្តសប្បុរសដោយប្រព្រឹត្តអំពើល្អចំពោះបងប្អូនឯទៀតផងដែរ។ ប្រសិនបើនៅក្នុងផាកជីវិតរបស់យើងទាំងមូល គឺជាពេលវេលាដើម្បីសាបព្រោះអំពើល្អ សូមយកពេលវេលាក្នុងឱកាសរដូវអប់រំពិសេសនេះជួយថែរក្សាបងប្អូនឯទៀតៗ ដើម្បីឱ្យយើងបានជិតស្និទ្ធជាមួយបងប្អូនរបស់យើង ដែលកំពុងមានរបួសនៅលើមាគ៌ានៃជីវិត(លូកា ១០,២៥-៣៧)។ រដូវអប់រំពិសេស គឺជាឱកាសដ៏ល្អ ដើម្បីស្វែងរក ហើយមិនមែនគេចចេញពីបងប្អូនដែលត្រូវការជំនួយឡើយ។ ចូរហៅ ហើយកុំធ្វើព្រងើយចំពោះអស់បងប្អូន ដែលត្រូវការស្ដាប់ពាក្យពេចន៍ដ៏ពិរោះ។ ចូរសួរសុខទុក្ខ និងកុំបោះបង់បងប្អូន ដែលរងទុក្ខដោយសារភាពឯកោ។ ចូរយើងប្រព្រឹត្តអំពើល្អចំពោះបងប្អូនទាំងអស់ ដោយយកពេលវេលាស្រឡាញ់បងប្អូនតូចតាច និងគ្មានទីពឹង បងប្អូនដែលត្រូវគេបោះបង់ចោល និងបងប្អូនដែលត្រូវគេមើលងាយ បងប្អូនជនរងគ្រោះដោយសារការរើសអើង និងបងប្អូនដែលគ្មានតម្លៃកំពុងឋិតនៅខាងក្រៅសង្គម (cf. Enc. Fratelli tutti, លេខ ១៩៣)។

### ៣. ប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ យើងនឹងច្រូតបានផលជាមិនខាន

រដូវអប់រំពិសេសរម្លឹកយើងជារៀងរាល់ឆ្នាំគឺ «អំពើល្អ សេចក្ដីស្រឡាញ់ យុត្តិធម៌ និងសាមគ្គីភាព មិនមែនធ្វើតែម្ដងរួចរាល់នោះទេ ត្រូវតែអនុវត្តជារៀងរាល់ថ្ងៃ» (*ឯកសារដដែល* លេខ ១១)។ ចូរអង្វរព្រះជាម្ចាស់ប្រទានឱ្យមានចិត្តអត់ធ្មត់ជានិច្ច ដើម្បីក្លាយជាអ្នកបង្កើតផល(យ៉ាកុប ៥,៧) ដែលប្រព្រឹត្តអំពើល្អជាប្រចាំ។ សូមឱ្យអស់បងប្អូនដែលដួលឈោងដៃចាប់ព្រះហស្ដព្រះជាម្ចាស់លើកខ្លួនឡើង។ សូមឱ្យបងប្អូនដែលវង្វេងស្មារតី បណ្ដោយខ្លួនធ្លាក់ទៅតាមការទាក់ទាញរបស់មារ បែរមករកព្រះអម្ចាស់វិញ «ព្រះអង្គមានព្រះហឫទ័យអត់ទោសទូលំទូលាយ» (អេសាយ ៥៥,៧)។ នៅក្នុងពេលវេលានៃការប្រែចិត្តគំនិតនេះ ចុះពឹងផ្អែកលើព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះជាម្ចាស់ និងពឹងផ្អែកលើការរួបរួមគ្នាជាធ្លុងតែមួយរបស់ព្រះសហគមន៍។ សូមយើងកុំនឿយណាយនឹងសាបព្រោះអំពើល្អឡើយ។ តមអាហារគឺជាការរៀបចំ

ដី អធិដ្ឋានគឺជាការស្រោចទឹក កិច្ចការសប្បុរសគឺជាការបង្កើតផល។ យើងទុកចិត្តច្បាស់លាស់នៅក្នុងជំនឿថា «យើងនឹងច្រូតបានផលជាមិនខាន ប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ» រួមនឹងអំណោយទានដោយចិត្តស៊ូទ្រាំ យើងនឹងទទួលផលតាមព្រះបន្ទូលសន្យា(ហេប្រឺ ១០,៣៦) សម្រាប់ការសង្គ្រោះរបស់យើង និងបងប្អូនឯទៀតជាមិនខាន(១ធីម៉ូថេ ៤,១៦)។ ការប្រព្រឹត្តសេចក្ដីស្រឡាញ់ជាភាតរភាពចំពោះមនុស្សគ្រប់គ្នា នាំយើងឱ្យរួបរួមជាមួយព្រះគ្រីស្ត ដែលបូជាព្រះជន្មរបស់ព្រះអង្គសម្រាប់យើង (២កូរិនថូស ៥,១៤-១៥) ដើម្បីប្រទានឱ្យយើងមានអំណរនៃព្រះរាជស្ថានបរមសុខ ដល់ពេលព្រះជាម្ចាស់ « គ្រងរាជ្យលើអ្វីៗទាំងអស់ក្នុងគ្រប់ប្រការទាំងអស់» (១កូរិនថូស ១៥,២៨)។

បពិត្រព្រះនាងម៉ារី ព្រះសង្គ្រោះបានចាប់កំណើតក្នុងផ្ទៃព្រះនាង
ព្រះនាងបានចងចាំហេតុទាំងអស់
ហើយថែមទាំងរិះគិតពិចារណា
នៅក្នុងដួងចិត្តទៀតផង (លូកា ២,១៩)។
សូមព្រះនាងប្រទានឱ្យយើងទទួលព្រះអំណោយទាននូវចិត្តស៊ូទ្រាំ
និងបានរួមជិតស្និទ្ធជាមួយព្រះអម្ចាស់តាមរយៈព្រះមាតាព្រះអង្គ
ដើម្បីឱ្យពេលវេលានៃការប្រែចិត្តគំនិតនេះ
ទទួលផលនៃការសង្គ្រោះអស់កល្បជានិច្ចផង។

ធ្វើនៅទីក្រុងរ៉ូម ព្រះវិសាលវិហារ សន្តយ៉ូហាន ឡាត្រង់
ក្នុងឱកាសបុណ្យរម្លឹកសន្តម៉ាតាំង ជាលោកអភិបាល
ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១

---

[1] Cf. SAINT AUGUSTIN , Serm. 243, 9,8 ; 270, 3 ; Fr. dans Ps. 110, 1.

[2] Cf. Moment extraordinaire de prière en temps d’épidémie ( 27 mars 2020 ).

[3] Cf. Angélus du 17 mars 2013.